**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣២...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែប្រែរចនាសម្ព័ន្ធនៃមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតមហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# សំ រេ ច

**មាត្រា ១ :** អនុញ្ញាតអោយ មហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ី កែប្រែរចនាសម្ព័ន្ធ ទៅជា វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង (Institute of Management Sciences) ហៅកាត់ជាភាសាខ្មែរ វ.វ.គ. និង ជាភាសាអង់គ្លេស I.M.S.។ វិទ្យាស្ថាននេះ មានទីតាំងមូលដ្ឋាន នៅអាគារជាប់ធនាគារកាណាឌីយ៉ា នៅផ្លូវព្រះកុសុមៈនារីរ័ត្ន ឃុំកំពង់ចាម ស្រុកកំពង់ចាម ក្នុងទីរួមខេត្ត កំពង់ចាម ។ រីឯ មហាវិទ្យាល័យវ៉ាស៊ីនតោនឌីស៊ីខេត្តបាត់ដំបង ត្រូវបានចាត់ទុកជា សាខានៃវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង វិញ ។

**មាត្រា ២ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សា ៤ ឆ្នាំ ត្រូវនឹង ១៥០ ក្រេឌីត ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មាន ៣ មហាវិទ្យាល័យ :

១. មហាវិទ្យាល័យគ្រប់គ្រង និង ទេសចរណ៍

២. មហាវិទ្យាល័យពត៌មានវិទ្យា

៣. មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច

ទៅពេលអនាគត វិទ្យាស្ថាននេះអាចបើក មហាវិទ្យាល័យ ឬសាខា ឬឯកទេសជំនាញ ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ត្រូវគោរព តាមបទដ្ឋាន របស់ក្រសួង អប់រំ យុវជន និង កីឡា ដែលកំណត់ អំពីការជ្រើសរើសអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៥ :** នាយក នៃ វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានភារកិច្ច :

- ជ្រើសរើស សិស្ស និស្សិតអោយចូលរៀន និង ជ្រើសរើស សាស្ត្រាចារ្យ មកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការងារស្រាវជ្រាវ ឯកសារសិក្សា ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆមាស ។

**មាត្រា ៦ :** ក្នុងរចនាសម្ព័ន្ធ នៃវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេច លើគោលនយោបាយនិងផែនការអភិវឌ្ឍវិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រ

មួយ សំរាប់ពិនិត្យ និង ផ្តល់ការយល់ព្រម លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៧ :** វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ត្រូវស្ថិតនៅក្រោម ឱវាទក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង និងទទួលជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញ និងអនុវត្ត តាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានវិទ្យាសាស្ត្រគ្រប់គ្រង មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ១០ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្តកំពង់ចាម
- សាលាខេត្តបាត់ដំបង

" ដើម្បីមុខការ "

- ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ